**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ....០៥៤.......ន. គ. ស/សរ.ស.ពា.

ថ្ងៃសុក្រ ១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គល ដែលមានជំនាញក្នុងការបង្រៀន

**និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស.**) គឺជាស្ថាប័ននិយ័តកម្មគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដើម្បីទទួលបានការជឿទុកចិត្តពីស្ថាប័នសាធារណៈ វិនិយោគិន ធុរជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ច របស់ខ្លួន **ន.គ.ស.** បានដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័នរយៈពេល ០៥ ឆ្នាំ (២០២១-២០២៥)។ ការអភិវឌ្ឍសមត្ថភាពមន្ត្រី គឺជាសកម្មភាពមួយនៃផែនការអភិវឌ្ឍន៍ស្ថាប័ន។ ក្នុងន័យនេះ **ន.គ.ស.** ត្រូវការជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គល ដើម្បីផ្តល់សេវាបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើការកសាងសមត្ថភាពមន្ត្រី **ន.គ.ស.** ទាំងចំណេះដឹងនិងការអនុវត្តលើជំនាញ÷ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង, បច្ចេកទេសនៃការពិនិត្យរបាយការណ៍ហិរញ្ញវត្ថុនិងបច្ចេកទេសស៊ីជម្រៅស្តង់ដា÷ CIFRS, CIFRS for SMEs និងNFPE ព្រមទាំងការត្រួតពិនិត្យគុណភាពសវនកម្ម។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលឬរូបវន្តបុគ្គលដែលមានគុណវុឌ្ឍិដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិសម្រាប់ជំនាញ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- មានបទពិសោធន៍បណ្តុះបណ្តាលរយៈពេល១០ឆ្នាំ
- ករណីជាក្រុមហ៊ុន ត្រូវចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មពេញលេញ សម្រាប់ក្រុមហ៊ុន។

### ២. លក្ខខណ្ឌគុណវុឌ្ឍិសម្រាប់ជំនាញ បច្ចេកទេសនៃការពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- មានបទពិសោធន៍បណ្តុះបណ្តាលពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យ និងសវនកម្មរយៈពេលលើសពី១០ឆ្នាំ
- មានជំនាញក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ និងការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
- បានចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

### ៣. លក្ខខណ្ឌគុណវុឌ្ឍិសម្រាប់ជំនាញ បច្ចេកទេសស៊ីជម្រៅស្តង់ដា÷ CIFRS, CIFRS for SMEs និងNFPE

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- មានបទពិសោធន៍បណ្តុះបណ្តាលពាក់ព័ន្ធនឹងស្តង់ដា CIFRS, CIFRS for SMEs និងNFPE រយៈពេលយ៉ាងតិច១០ឆ្នាំ
- បានចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ

- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

## ៤.លក្ខខណ្ឌគុណវុឌ្ឍិសម្រាប់ជំនាញ ការត្រួតពិនិត្យគុណភាពសវនកម្ម

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- មានបទពិសោធន៍បណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារសវនកម្ម រយៈពេលយ៉ាងតិច១០ឆ្នាំ
- មានចំណេះដឹងនិងបទពិសោធន៍ការអនុវត្តលើ IFRS និង Audit quality (ISQC1/ISQM1)
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

## ៥. សមិទ្ធផលដែលត្រូវផ្តល់

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គល ដែលទទួលជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ជូន **ន.គ.ស.** នូវស្ថានភាពនៃការអនុវត្តកាតព្វកិច្ចរបស់អ្នកជាប់កាតព្វកិច្ច និងការវិភាគលម្អិតនិងស៊ីជម្រៅអំពីការអនុវត្តកាតព្វកិច្ចជាអាទិ៍÷

- ផែនការក្នុងការបង្រៀនទាក់ទងទៅនឹងជំនាញដែល **ន.គ.ស.** មានតម្រូវការ
- ការបង្រៀន ការសង្កេត និងការប្រមូលទិន្នន័យនៃមេរៀនបច្ចេកទេស
- ការវាយតម្លៃ និងមតិកែលម្អ។

## ៦. កម្រៃ

កម្រៃសម្រាប់ការបង្រៀននេះ គឺបើកចំហរសម្រាប់ការចរចារ។

## ៧. រយៈពេលសម្រាប់ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលមានរយៈពេលអាស្រ័យលើជំនាញនីមួយៗ និងតាមការពិភាក្សា។

កិច្ចសន្យានៃការផ្តល់សេវាមួយ នឹងត្រូវបង្កើតឡើងរវាង **ន.គ.ស.** ជាមួយនឹងក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គលដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

## ៨. ការដាក់ពាក្យ

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គល មានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh ត្រឹមថ្ងៃទី១៤ ខែសីហាឆ្នាំ២០២២ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

ចំពោះ ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬរូបវន្តបុគ្គល ដែលបានជាប់ក្នុងបញ្ជីសម្រាំងនឹងត្រូវបានជូនដំណឹង។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទំនាក់ទំនង និងតេឡេក្រាម ÷ ០៦៩ ៧៨ ៣៩ ៣៦

**និយ័តករគណនេយ្យនិងសវនកម្ម**